00158974

ឯកសារ/Nº D55/I

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24 / 01 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចបដិសេធបណ្តឹងសុំមោឃភាព
# Order Refusing a Request for Annulment
# Ordonnance de rejet d'une requête en nullité

ORIGINAL DOCUMENT
RECEIVED ON 24-01-2008
AT: 15:15 PM
BY SANN RADA
COURT OFFICER

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤
បានឃើញវិធាន ៤៨ វិធាន ៦៣ និង វិធាន ៧៦ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **នួន ជា**

ត្រូវដាក់អោយស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និង ការរំលោភបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ១៩៤៩ ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៥ មាត្រា ៦ មាត្រា ២៩ ថ្មី និងមាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញថ្ងៃទី២៧ តុលា ២០០៤។

## <u>បណ្តឹងរបស់មេធាវីការពារក្តី</u>

១- តាមរយៈពាក្យបណ្តឹងចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០០៧ មេធាវីរបស់ **នួន ជា** ស្នើសុំមោឃភាពកំណត់ហេតុនៃការចូលខ្លួនដំបូង (D-20) កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល (C-8) និង កំណត់ហេតុនៃការសួរចម្លើយចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៧ (D-23)។ ដោយដកស្រង់ទឡ្ហីករណ៍ដែលធ្វើឡើងនៅក្នុងកថាខណ្ឌទី ៤ ដល់ ១៤ នៃសារណា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ដើម្បីគាំទ្រដល់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន (C-11/4) ដែលបច្ចុប្បន្នកំពុងរង់ចាំការសម្រេចពីអង្គបុរេជំនុំជម្រះ និង ដោយបន្ថែមខ្លឹមសារថា៖

- សហចៅក្រមស៊ើបអង្កេតមិនត្រូវរៀបចំឲ្យមានការចូលខ្លួនដំបូង និងកិច្ចពិភាក្សាវែងឆ្ងាយ ដោយមិនមានវត្តមានរបស់មេធាវីការពារក្តីឡើយ។ បើតាមមេធាវីការពារក្តី ស្ថានភាពបែបនេះបានរំលោភសិទ្ធិជាច្រើនរបស់កូនក្តីខ្លួន (សិទ្ធិដែលត្រូវមានជំនួយពីមេធាវី សិទ្ធិទទួលបាននូវនីតិវិធីចំពោះមុខ សិទ្ធិដែលត្រូវមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារកូនក្តីរបស់ខ្លួន សិទ្ធិក្នុងការនៅស្ងៀម និងសមភាពនៃគូភាគី) ។ មេធាវីការពារក្តី អះអាងថា *"ការលះបង់ដែលមានលក្ខណៈជាខាងក្រៅ នូវសិទ្ធិដែលត្រូវមានជំនួយពីមេធាវីរបស់លោក នួន ជា គឺមានលក្ខណៈអត្ថន័យ និងស្រពិចស្រពិល ហើយវាមិនបានកើតចេញពីសេចក្តីសម្រេចដែលបានធ្វើឡើងដោយបានដឹងពីមូលហេតុនោះទេ"*។

- សហចៅក្រមស៊ើបអង្កេតមិនគួរបន្តការសួរចម្លើយនៅថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៧ ដោយមិនគិតអំពីការជំទាស់របស់មេធាវីការពារក្តី និងរបស់ជនត្រូវចោទ ដែលលើកឡើងអំពី *"ការយល់ដឹងរឿងក្តីមានកម្រិតរបស់មេធាវីការពារក្តី និងស្ថានភាពសុខភាពមិនរឹងប៉ឹងរបស់លោក នួន ជា"* ទេ។

## **<u>សំអាងហេតុនៃសេចក្តីសម្រេច</u>**

### **<u>ទាក់ទិននឹងការចូលខ្លួន</u>**

២. ជាការសំខាន់ដែលគួររំលឹកថា ការចូលខ្លួនលើកដំបូងបានប្រព្រឹត្តទៅស្របនឹងវិធាន ៥៧។ លោក នួន ជា ត្រូវបានឃាត់ខ្លួន តាមរយៈការអនុវត្តន៍ដីកាបង្គាប់ឲ្យនាំខ្លួន និងបានបញ្ជូនពីផ្ទះរបស់គាត់មកកាន់ អ.វ.ត.ក ដោយឧទ្ធម្ភាគចក្រ ដើម្បីកាត់បន្ថយការនឿយហត់ដោយការធ្វើដំណើរ។ បន្ទាប់មក ម៉ោងនៃការចូលខ្លួនដំបូងត្រូវបានលើកពេលដើម្បីអាចឲ្យលោក នួន ជា បានស្រួលខ្លួន បន្ទាប់ពីការធ្វើដំណើរ និងអាចទទួលទានបាយបាន។ បន្ទាប់មកទៀត លោក នួន ជា ត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ ស្របតាមវិធាន ៥៧ (១)។ ម្យ៉ាងវិញទៀត ដោយជនត្រូវចោទ នៅមិនទាន់មានមេធាវីការពារនៅឡើយ គាត់ត្រូវបានប្រាប់ឲ្យដឹងយ៉ាងច្បាស់អំពីសិទ្ធិមានមេធាវី ។ ដូច្នេះគាត់បានឆ្លើយថា *"ខ្ញុំសូមជ្រើសរើសយកលោកមេធាវី សុន អរុណ។ ចំពោះការជ្រើសរើសយកមេធាវីបរទេសវិញ ខ្ញុំនឹងពិភាក្សាជាមួយនឹងមេធាវីរបស់ខ្ញុំ សុន អរុណ នៅពេលក្រោយ"*។ បន្ទាប់មកលោក នួន ជា ត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិក្នុងការនៅស្ងៀម និងប្រាប់ថាប្រសិនបើគាត់ចង់ធ្វើសេចក្តីថ្លែងការណ៍ណាមួយ សេចក្តីថ្លែងការណ៍នោះ នឹងត្រូវបានកត់ត្រាទុកភ្លាម។ លោក នួន ជា ក៏ត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិក្នុងការពិគ្រោះយោបល់ជាមួយមេធាវី



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ECCC * CETC CO-INVESTIGATING JUDGES / CO-JUGES D'INSTRUCTION

របស់ខ្លួនមុនត្រូវបានសួរចម្លើយ និងសិទ្ធិសំណូមពរឲ្យមេធាវីរបស់ខ្លួនមានវត្តមានមុននឹងខ្លួនធ្វើសេចក្តីថ្លែងការណ៍។ គាត់បានប្រកាសថា *“ខ្ញុំចង់ធ្វើសេចក្តីថ្លែងការណ៍ ទោះបីជាអវត្តមានមេធាវីរបស់ខ្ញុំក៏ដោយ”*។

៣. ការយល់ឃើញថា ការលះបង់សិទ្ធិដែលត្រូវមានជំនួយពីមេធាវីធ្វើឡើងតាមរបៀបនេះអាចត្រឹមតែ “ជាលក្ខណៈខាងក្រៅ អធន្ទះ និងមានលក្ខណៈមិនច្បាស់លាស់” នោះ នាំឲ្យការអនុវត្តន៍ វិធាន ៥៧ នឹងប្រាសចាក អត្ថន័យរបស់ខ្លួន ដែលចែងថា *“ប្រសិនបើជនត្រូវចោទយល់ព្រមធ្វើសេចក្តីថ្លែងការណ៍នោះ សេចក្តីថ្លែងការណ៍នោះនឹងត្រូវបានកត់ត្រាទុកភ្លាមដោយសហចៅក្រមស៊ើបអង្កេត”*។ ចំពោះរឿងនេះ លោក នួន ជា បានជ្រើសរើសយកការធ្វើសេចក្តីថ្លែងការណ៍ដើម្បី *“ទាត់ចោលទាំងស្រុងនូវរាល់បទចោទទាំងអស់”* ប្រឆាំងនឹងរូបគាត់ ដែលនេះជាសិទ្ធិដ៏ត្រឹមត្រូវរបស់គាត់ ហើយការបដិសេធសិទ្ធិនេះចំពោះគាត់គឺជាការបដិសេធសេរីភាពរបស់គាត់ទាំងស្រុងក្នុងនាមជាមនុស្សដែលមានហេតុផលត្រឹមត្រូវ។

៤. ចំនុចសំខាន់ដែលមិនអាចសង្ស័យបានគឺចៅក្រមបានផ្តល់ការបំភ្លឺចាំបាច់ទាំងអស់យ៉ាងក្បោះក្បាយគ្រប់គ្រាន់ដើម្បីឲ្យមានការយល់ច្បាស់ពីនីតិវិធី យន្តការតុលាការដែលវិនិច្ឆ័យភាគច្រើនកម្រនឹងទទួលបាននូវយន្តការរបៀបនេះណាស់។ ព្រមជាមួយគ្នានេះដែរ គួររំលឹកផងដែរថា អ្នកដឹកនាំនយោបាយមួយរូប ទោះបីជាមានវ័យចំណាស់បន្តិចក៏ដោយ ច្បាស់ជាមានសមត្ថភាពយល់ដឹងជាងសមត្ថភាពដែលវិនិច្ឆ័យធម្មតាមាន។

៥. តាមការពិតទៅ ជាការពិបាកណាស់ដែលនឹងគិតថា អាចមានស្ថានភាពមួយ ដែលការបោះបង់សិទ្ធិមានវត្តមានមេធាវីមានលក្ខណៈច្បាស់លាស់ និងប្រកបដោយឆន្ទះ ជាងស្ថានភាពនៃរឿងក្តីនេះណាស់ លើកលែងតែសមត្ថភាពបញ្ញារបស់លោក នួន ជា ចោទជាបញ្ហាឡើង ដែលករណីនេះទំនងជានឹងមិនអាចដូច្នេះទេ។

៦. ជាចុងក្រោយ គួរកត់សំគាល់ថា ទោះបីវាមិនបានបង្ហាញច្បាស់នៅក្នុងពាក្យបណ្តឹងក៏ដោយ មេធាវីការពារក្តីដែលយោងដល់បទប្បញ្ញត្តិនៃវិធាន ៥៨ (២) *(“ការសួរចម្លើយជនត្រូវចោទត្រូវតែធ្វើឡើងដោយមានវត្តមានរបស់មេធាវី លើកលែងតែជនត្រូវចោទយល់ព្រមឆ្លើយដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ខ្លួនដោយសរសេរចូលក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរមួយដោយឡែកដោយមានហត្ថលេខា ឬស្នាមមេដៃរបស់ជនត្រូវចោទ ហើយត្រូវបញ្ចូលទៅក្នុងសំណុំរឿង។ ការយល់ព្រមឆ្លើយដោយមិនចាំបាច់មានមេធាវីរបស់ជនត្រូវចោទត្រូវថតទុកដូចមានចែងនៅក្នុងវិធាន ២៥”)* មានការភ័ន្តច្រឡំរវាងវិធានដែលអនុវត្តនៅពេលចូលខ្លួនលើកដំបូង និងវិធានដែលសម្រាប់អនុវត្តនៅពេលសួរចម្លើយពេលក្រោយមកទៀត។

ដោយផ្អែកលើអំណះអំណាងទាំងនេះ ការចូលខ្លួនដំបូងមានលក្ខណៈត្រឹមត្រូវពិតប្រាកដ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

00158977



**ទាក់ទិននឹងកិច្ចពិភាក្សាដេញដោល**

៧. បន្ទាប់ពីការចូលខ្លួនដំបូង ជនត្រូវចោទត្រូវបានឱ្យដឹងថា កិច្ចពិភាក្សាដេញដោលមួយនឹងត្រូវបានរៀបចំឡើង ដើម្បីសម្រេចជាយថាហេតុអំពីការឃុំខ្លួនជាបណ្ដោះអាសន្ន។ លោក នួន ជា ត្រូវបានប្រាប់ឱ្យដឹងយ៉ាងច្បាស់អំពីសិទ្ធិរបស់ខ្លួន ហើយបានធ្វើការកត់សំគាល់ថា៖ *"ទោះបីជា មេធាវីរបស់ខ្ញុំមិនទាន់មានវត្តមានក៏ដោយ ក៏ខ្ញុំចង់ឱ្យមានកិច្ចពិភាក្សាដេញដោលភ្លាមៗដែរ"*។

៨. មុននឹងចាប់ផ្ដើមកិច្ចពិភាក្សាដេញដោល សហចៅក្រមស៊ើបអង្កេតបានរំលឹកដល់ជនត្រូវចោទថា ជនត្រូវចោទបានជ្រើសរើសមេធាវីកម្ពុជា សុន អរុណ។ ចៅក្រមស៊ើបអង្កេត ដែលនៅតែចង់ឱ្យមានវត្តមានរបស់មេធាវីនោះ បានប្រាប់ឱ្យជនត្រូវចោទដឹងថា មេធាវីរបស់គាត់អាចមកដល់ អ.វ.ត.ក តែនៅថ្ងៃស្អែកប៉ុណ្ណោះ ដែលដូចនេះបានគូសបញ្ជាក់នៅក្នុងនោះអំពីលទ្ធភាពនៃការពន្យារពេលនៃការរៀបចំកិច្ចពិភាក្សាដេញដោល។ ប៉ុន្តែលោក នួន ជា បានឆ្លើយតបថា ៖ *"ទោះបីជា មេធាវីរបស់ខ្ញុំមិនទាន់មានវត្តមានក៏ដោយ ក៏ខ្ញុំចង់ឱ្យមានកិច្ចពិភាក្សាដេញដោលភ្លាមៗ"*។

៩. អ្នកស្រី ជា លាង ក្នុងនាមសហព្រះរាជអាជ្ញា បានព្យាយាមបញ្ចុះបញ្ចូលជនត្រូវចោទថា ប្រហែលជាផលប្រយោជន៍របស់ជនត្រូវចោទ ប្រសិនបើគាត់មានមេធាវីនៅជាមួយគាត់ ហើយបានស្នើសុំឱ្យយើងពន្យល់សារជាថ្មីអំពីអត្ថន័យពិតប្រាកដនៃកិច្ចពិភាក្សាដេញដោលដើម្បីជៀសវាងកុំឱ្យមានភាពស្រពិចស្រពិល។

១០. លោកសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង បាននិយាយឡើងវិញថា *"ដូចដែលមានបញ្ជាក់ក្នុងកំណត់ហេតុនៃការចូលខ្លួនដំបូង លោក Marcel Lemonde បានពន្យល់យ៉ាងច្បាស់អំពីបញ្ហា ទាក់ទិននឹងវត្តមានរបស់មេធាវីនេះ ហើយជនត្រូវចោទបានឆ្លើយថា៖ "សម្រាប់ពេលនេះ ខ្ញុំមិនត្រូវការមេធាវីទេ"*។

១១. លោក នួន ជា បានអះអាងជាថ្មីពីការសម្រេចចិត្តរបស់ខ្លួនជាចុងក្រោយ និងបានបញ្ជាក់ពីការយល់ច្បាស់អំពីផលវិបាកនៃការសម្រេចចិត្តរបស់ខ្លួន ដោយបានប្រកាសលះបង់សិទ្ធិមានវត្តមានមេធាវីជាបណ្ដោះអាសន្ន សម្រាប់តែការពិភាក្សាដេញដោលដើម្បីសម្រេចអំពីការឃុំខ្លួនប៉ុណ្ណោះ ៖ *"បាទ ប្រាកដណាស់ខ្ញុំត្រូវការមេធាវី ប៉ុន្តែវត្តមានរបស់គាត់មិនចាំបាច់ទេនៅពេលនេះ។ ខ្ញុំអាចការពារខ្លួនឯងបាននៅពេលនេះ ហើយចាប់ពីពេលស្អែកទៅ ខ្ញុំសុំឱ្យមេធាវីរបស់ខ្ញុំជាអ្នកការពារខ្ញុំ"*។

១២. មាត្រា ១៤-៣ (ឃ) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងយ៉ាងច្បាស់អំពីលទ្ធភាពសម្រាប់ជនត្រូវចោទក្នុងការការពារខ្លួនដោយខ្លួនឯង វាមិនមានលទ្ធភាពណាដែលអាចឱ្យសហចៅក្រមស៊ើបអង្កេតអាច



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ទទួ ចទាមទារលើសពីនេះបានទេ លើកលែងតែធ្វើការបដិសេធទាំងស្រុង នូវជម្រើសដោយសេរីរបស់ជនត្រូវចោទប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេត មិនអាចធ្វើកិច្ចការឲ្យលើសអំពីការបំភ្លឺសិទ្ធិនេះរបស់លោក នួន ជា បានឡើយ។

១៣. នៅក្នុងលក្ខខណ្ឌបែបនេះហើយទើបកិច្ចពិភាក្សាដេញដោលបានចាប់ផ្តើមឡើង។ នៅក្នុងសារណានៃបណ្តឹងឧទ្ធរណ៍ដែលពាក្យបណ្តឹងនេះយោងដល់ មេធាវីការពារក្តីទំនងជាបន្ទោសសហចៅក្រមស៊ើបអង្កេតថាមិនបានរំលឹកនៅម៉ោង ១៦:២៥ នាទី អំពីសិទ្ធិនៅស្ងៀមមិននិយាយស្តីដែលបានប្រាប់ដល់ជនត្រូវចោទនៅពេលចាប់ផ្តើមនៃការចូលខ្លួនលើកដំបូង (នៅម៉ោង ១៤:៤០ នាទី)។ នៅទីនេះ វាជាការចាំបាច់ដែលត្រូវរំលឹកថា ទាំងកិច្ចពិភាក្សាដេញដោល ឬកិច្ចស៊ើបសួរដែលបន្តមកទៀត មិនបង្កើតបានជា "ដំណាក់កាល" ថ្មី នៃនីតិវិធី ទៅតាមន័យនៃវិធាន ២១ នៃវិធានផ្ទៃក្នុងដែលមានចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិទូទៅថា ជនសង្ស័យ ឬជនត្រូវចោទ ត្រូវប្រាប់ឲ្យដឹងអំពីសិទ្ធិនៅស្ងៀមមិននិយាយស្តី "នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី" ដែលនេះមានន័យថានៅពេលអង្កេតបឋម នៅពេលចាប់ផ្តើមការស៊ើបសួរ និង នៅពេលបើកសវនាការជំនុំជម្រះសាលាដំបូង និង តុលាការកំពូល។

១៤. សហព្រះរាជអាជ្ញាបានសម្រេចដាក់ជូននូវឯកសារថ្មីដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត Marcel Lemonde បានកត់សម្គាល់ថា ការគោរពគោលការណ៍ចំពោះមុខតម្រូវអោយយើងផ្តល់ពេលវេលាមួយសម្រាប់ជនត្រូវចោទអាចពិនិត្យមើលឯកសារទាំងនោះជាមុនសិន។ ប៉ុន្តែលោក នួន ជា ជាថ្មីម្តងទៀតបានលះបង់សិទ្ធិទទួលបានពេលវេលាបន្ថែមនេះ ដោយប្រកាសថា ៖ *"ខ្ញុំអាចឆ្លើយបាន ដោយមិនចាំបាច់អានឯកសារដែលមានភ្ជាប់មកជាមួយទេ"។* បន្ទាប់មក ជនត្រូវចោទបានប្រកែកតវ៉ាម៉ឺងម៉ាត់ និងយ៉ាងដាច់អហង្ការ តទល់នឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយខិតខំធ្វើឲ្យសហចៅក្រមស៊ើបអង្កេតជឿថា ការឃុំខ្លួនគាត់បណ្តោះអាសន្នមិនមានសំអាងត្រឹមត្រូវឡើយ។ ពាក្យពេចន៍ដែលគាត់បានប្រើដើម្បីការពារខ្លួន សម្រាប់អ្នកសង្កេតការណ៍អព្យាក្រឹតទាំងអស់ ឆ្លុះបញ្ចាំងឲ្យឃើញថាគាត់មានមធ្យោបាយតទល់ពេញលេញគ្រប់គ្រាន់ទាំងអស់។ ដូច្នេះ ជាការមិនត្រឹមត្រូវទេ ដែលចោទជាបញ្ហាចំពោះសមត្ថភាពរបស់ជនត្រូវចោទ និងដែលគិតថាការប្រកាសទាំងអស់របស់គាត់មិនមែនជាទង្វើ របស់ជនដែលមានសមត្ថភាពគ្រប់គ្រាន់។

អាស្រ័យហេតុនេះ កិច្ចពិភាក្សាដេញដោលបានប្រព្រឹត្តទៅដោយមានការគោរពដល់សិទ្ធិនៃការការពារក្តីត្រឹមត្រូវ។

**<u>ទាក់ទិននឹងការសួរចម្លើយថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៧</u>**

១៥. តាំងពីពេលដំបូងនៃការសួរចម្លើយ ដែលក្នុងកំឡុងពេលទាំងមូលនៃការសួរចម្លើយនោះខ្លួនក៏មានវត្តមានដែរ មេធាវី សុន អរុណ បានលើកឡើងថា ខ្លួនបានដាក់ពាក្យស្នើសុំជាលាយល័ក្ខអក្សរ ដើម្បីស្នើសុំពន្យារពេលការ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

សួរចម្លើយនេះ ដោយបានបញ្ជាក់ថា លោកមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យសំណុំរឿង និងដោយបានបន្ថែមថា *"ខ្ញុំសូមស្នើសុំសហចៅក្រមស៊ើបអង្កេតសម្រេចលើចំនុចនេះ"*។ សហចៅក្រមស៊ើបអង្កេតបានធ្វើការកត់សំគាល់ថា រយៈពេលកំណត់ដែលមានចែងនៅក្នុងវិធាន ៥៨(១) នៃវិធានផ្ទៃក្នុងត្រូវបានគោរព ហេតុដូច្នេះមិនចាំបាច់មានការលើកពេលនៃការសួរចម្លើយទេ។

១៦. ប៉ុន្តែក្នុងការឆ្លើយតបនឹងសំណួរទី ១ របស់ចៅក្រមស៊ើបអង្កេត លោក នួន ជា បានឆ្លើយថា សុខភាពរបស់គាត់មិនល្អទេ៖ *"យប់មិញ ខ្ញុំដេកមិនលក់ ហើយសំពាធឈាមបានឡើងរហូតដល់ ១៦ ១៧ ១៨។ ខួរក្បាលខ្ញុំមិនសូវស្រួល ដូច្នេះខ្ញុំស្នើសុំសហចៅក្រមស៊ើបអង្កេតពិចារណាអំពីបញ្ហានេះ"*។

១៧. ដោយចៅក្រមមិនដែលត្រូវបានជូនដំណឹងណាមួយទាល់តែសោះពីសំណាក់វេជ្ជបណ្ឌិតដែលនៅប្រចាំការពិនិត្យសុខភាពរបស់ជនជាប់ឃុំ អំពីបញ្ហាសុខភាពណាមួយនោះ ជាហេតុនាំឲ្យចៅក្រមមានការសង្ស័យខ្លះៗទៅលើអាការៈជម្ងឺពិតប្រាកដរបស់ជនត្រូវចោទ និងមូលហេតុនៃសំណើសុំពន្យារពេលជាបន្តបន្ទាប់ (ដំបូងសុំពន្យារពេលដោយសារត្រូវការពេលវេលារៀបចំការការពារក្តី បន្ទាប់មកដោយសារបញ្ហាសុខភាពវិញ) និងនាំឲ្យគិតថានេះអាចជាឥរិយាបទមួយសម្រាប់ការពន្យារពេល។

១៨. ជនត្រូវចោទត្រូវបានអនុញ្ញាតយ៉ាងជាក់ច្បាស់ឲ្យប្រាប់មកសហចៅក្រមស៊ើបអង្កេតដោយផ្ទាល់ ឬ តាមរយៈមេធាវី ថាខ្លួនចង់ប្រើប្រាស់សិទ្ធិនៅស្ងៀមមិននិយាយស្តី ហើយអំណើះតទៅបដិសេធឆ្លើយតបរាល់សំណួរទាំងអស់។ ប៉ុន្តែ នៅពេលនោះជនត្រូវចោទមិនបានប្រកាន់យកឥរិយាបទបែបនេះឡើយ។ ក្នុងពេលកិច្ចពិភាក្សាដេញដោល លោក **នួន ជា** បានប្រកាសថា *"ខ្ញុំចង់បំភ្លឺដល់ប្រជាជនកម្ពុជា និង ពិភពលោកទាំងមូលឲ្យដឹងថាអ្នកណាជាមិត្ត និង អ្នកណាជាសត្រូវ"*។ ក្នុងពេលសួរចម្លើយនាថ្ងៃទី ២៦ ខែ កញ្ញាឆ្នាំ ២០០៧ ជនត្រូវចោទពន្យល់ថា *"ប្រសិនបើលោកចៅក្រមអនុញ្ញាតអោយខ្ញុំសម្រាក ខ្ញុំអាចបំភ្លឺដល់តុលាការនាពេលក្រោយបាន"* ។ អាកប្បកិរិយានេះនៅបន្តដដែលនាពេលសួរចម្លើយបន្ទាប់គឺនៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០០៧ ដែលនៅពេលនោះជនត្រូវចោទលើកឡើងថា " *ទីមួយ ជើងរបស់ខ្ញុំហើម។ ទីពីរ ខ្ញុំវិលមុខ ហើយស្តាប់មិនសូវបាន។ ទីបី សម្ពាធឈាមមិននឹងនរ ហើយទីបួន បេះដូងរបស់ខ្ញុំដើរមិនសូវស្រួលដោយសារជម្ងឺផ្តាស់សាយ"* ។ ចំណែកឯមេធាវីរបស់ជនត្រូវចោទបានស្នើសុំអោយមានការលើកពេលសារជាថ្មី ដោយអះអាងថាខ្លួនមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យមើលរឿងក្តីឡើយ (ការលើកពេលដែលត្រូវបានផ្តល់អោយនៅពេលនោះ)។ នៅទីបញ្ចប់ នាពេលសួរចម្លើយ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០០៧ ជនត្រូវចោទបានប្រាប់យ៉ាងច្បាស់ថា ខ្លួនមិនចង់ឆ្លើយទៅនឹងសំណួរទាំងឡាយទេ "*នៅពេលនេះ*"។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ចារ០/ល-D55/I

១៩. ជម្រើសនៃទឡ្ហីករណ៍ដែលបានលើកឡើង ទោះតាមវិធីណាក៏ដោយ ជាសិទ្ធិរបស់មេធាវីការពារក្តី ប៉ុន្តែចៅក្រមមានសិទ្ធិបង្ហាញភាពបញ្ច្រាស់គ្នាដែលអាចមានជាយថាហេតុ។ ម្យ៉ាងវិញទៀត ការគោរពនូវសិទ្ធិការពារក្តីមិនត្រូវច្រឡូកច្របល់គ្នាជាមួយសិទ្ធិរបស់ជនត្រូវចោទនៅក្នុងការធ្វើអោយរាំងស្ទះដល់នីតិវិធីឡើយ។ ចៅក្រមមានកាតព្វកិច្ចមិនត្រឹមតែធានាអោយមានការគោរពនូវគោលការណ៍នីតិវិធីចំពោះមុខ ប៉ុន្តែត្រូវធានានូវដំណើរការក្តីមួយដែលមិនយឺតយ៉ាវហួសហេតុផងដែរ។

២០. មិនមែនជារឿងចម្លែកទេដែលសហចៅក្រមស៊ើបអង្កេតបានបដិសេធផ្តល់ការយល់ព្រមដល់ការស្នើសុំលើកទីមួយអោយមានការពន្យារពេលដោយមិនមានការផ្ទៀងផ្ទាត់ផ្សេងទៀត ហើយបែរជាបង្គាប់មានការធ្វើកោសលវិច័យ (នាវេលាម៉ោង ១០ និង ៤០នាទី ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៧) មុនពេលធ្វើការសម្រេច។ ការពិនិត្យនេះបានបង្ហាញយ៉ាងជាក់ច្បាស់ថាមានករណីលើសឈាមមែន ដែលនាំអោយការសួរចម្លើយមិនអាចប្រព្រឹត្តទៅបាន (ករណីលើសឈាមនេះជារោគវិនិច្ឆ័យ ដែលតាមរយៈការធ្វើកោសលវិច័យក្រោយមកទៀត អាចគ្រប់គ្រងបានដោយការលេបថ្នាំ និងមិនមានបម្រាមណាមួយជាពិសេសពាក់ព័ន្ធទៅនឹងការចូលរួមរបស់ជនត្រូវចោទនៅក្នុងការស៊ើបសួរឡើយ)។ បើទោះបីជាយើងចាត់ទុកថា ការបដិសេធមិនព្រមលើកពេលសួរចម្លើយរបស់ចៅក្រមជាប្រការដែលអាចរិះគន់បាន ប៉ុន្តែវាជាការលំបាកណាស់ក្នុងការកំណត់ថាតើការបដិសេធនេះបានបង្កការខូចខាតអ្វីដល់ជនត្រូវចោទ ដោយហេតុថាជនត្រូវចោទមិនបានផ្តល់នូវសេចក្តីប្រកាសអ្វីឡើយ។ កំណត់សំគាល់នេះនាំអោយយើងចោទសួរអំពីភាពដែលអាចទទួលយកបាននៃបណ្តឹងសុំមោឃភាពនៅត្រង់ចំណុចជាក់លាក់នេះ ដោយអនុលោមតាមវិធាន ៤៨ នៃវិធានផ្ទៃក្នុង ដែលចែងថាគ្មានកិច្ចណាមួយអាចត្រូវចាត់ទុកជាមោឃៈចំពោះករណីមិនគោរពវិធានបញ្ញត្តិឡើយ ប្រសិនបើកិច្ចនោះមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំទេ។

២១. ជារួម មិនមានដំណាក់កាលណាមួយនៃការចូលខ្លួនលើកដំបូង កិច្ចពិភាក្សាដេញដោល ឬពេលសួរចម្លើយនាថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៧ ដែលមានការគម្រាមកំហែង ការសន្យា ឬការញុះញង់ដោយជាក់លាក់ ឬ ដោយមិនជាក់លាក់ ក្នុងគោលបំណងជម្រុញលោក **នួន ជា** អោយនិយាយដោយមិនមានវត្តមានរបស់គាត់ ឬ ដែលអាចអោយយល់ឃើញថា វត្តមានរបស់មេធាវីបានស្ថិតនៅក្នុងលក្ខខណ្ឌ ឬ អាចត្រូវបានធ្វើអោយយឺតយ៉ាវឡើយ។ សិទ្ធិរបស់ជនត្រូវចោទត្រូវបានជូនដំណឹងយ៉ាងច្បាស់ គ្មានភាពស្រពិចស្រពិល ហើយស៊ីជម្រៅ និង ត្រូវបានគោរពនៅគ្រប់កិច្ចនីតិវិធីដែលបានចោទប្រកាន់។

ដោយពិនិត្យមើលលើចំនុចទាំងអស់នេះ បណ្តឹងសុំមោឃភាពមិនមានសំអាងត្រឹមត្រូវឡើយ និង មិនអាចប្តឹងទៅអង្គបុរេជំនុំជម្រះឡើយ។

## ហេតុដូច្នេះ សម្រេច

មិនប្តឹងទៅអង្គបុរេជំនុំជម្រះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**
**Co- Investigating Judges**
**Co-juges d'instruction**

MARCEL Lemonde　　យូ ប៊ុនឡេង

ដីកាសម្រេចនេះតាក់តែងឡើងជាភាសាខ្មែរ និង ភាសាបារាំង និង បកប្រែជាភាសាអង់គ្លេសជាក្រោយ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.